# បញ្ហានានាដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី



ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
សាស្ត្រាចារ្យ Fukuoka Fumie និង Umemoto Yumi

# ប្រធានបទលើកនេះ

1 ការធ្វើកិច្ចសន្យា

2 ការលុបចោលកិច្ចសន្យា

3 ការរំលាយកិច្ចសន្យា

# 1 ការធ្វើកិច្ចសន្យា

# Q. ជាការចាប់ផ្ដើម តើអ្វីទៅជាកិច្ចសន្យា?

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច។(CC311)

① កិច្ចសន្យាដែលមានឆន្ទៈត្រូវគ្នា
② គោលបំណងនៃឆន្ទៈរបស់ភាគីឆ្ពោះទៅរកការបង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ច

# Q. តើកិច្ចសន្យាមានប្រភេទបែបណាខ្លះ?

កិច្ចសន្យាអញ្ញមញ្ញ ៖ កិច្ចសន្យាដែលភាគីទាំងសងខាងមានកាតព្វកិច្ច ដែលកាតព្វកិច្ចនោះ មានទំនាក់ទំនងជាតម្លៃថ្នូរទៅវិញទៅមក។

ឧទា) ការលក់ទិញ(CC515)

កិច្ចសន្យាឯកតោភាគី ៖ កិច្ចសន្យាដែលភាគីតែម្ខាងត្រូវទទួលបន្ទុកកាតព្វកិច្ច។

ឧទា) ប្រទានកម្ម(CC568) ការខ្ចីប្រើ(CC625)

កិច្ចសន្យាដែលយកតម្លៃថ្នូរ (មូលា) ៖ កិច្ចសន្យាដែលមានតាវកាលិកតបផ្នែកសេដ្ឋកិច្ច។

ឧទា) ការលក់ទិញ

កិច្ចសន្យាដែលមិនយកតម្លៃថ្នូរ (មុធា) ៖ កិច្ចសន្យាដែលមិនមានតាវកាលិកតបផ្នែកសេដ្ឋកិច្ច។

ឧទា) ប្រទានកម្ម

កិច្ចសន្យាដោយការព្រមព្រៀង ៖ កិច្ចសន្យាដែលធ្វើឡើងដោយគ្រាន់តែមានការព្រមព្រៀង គ្នារវាងគូភាគីតែប៉ុណ្ណោះ។

ឧទា) ការលក់ទិញ ប្រទានកម្ម ការខ្ចីបរិភោគ(CC579) ភតិសន្យា(CC597)

កិច្ចសន្យាដោយមានការប្រគល់វត្ថុ ៖ កិច្ចសន្យាដែលមានភាពចាំបាច់នៃការ ទទួលកម្មវត្ថុដើម្បីបង្កើតកិច្ចសន្យា។

ឧទា) ការខ្ចីប្រើ បញ្ញើ(CC670)

Q. តើកិច្ចសន្យាត្រូវបង្កើតឡើងតាមរយៈអ្វី?

ជាគោលការណ៍ គឺបង្កើតឡើងតាម**ការព្រមព្រៀងតែប៉ុណ្ណោះ**(CC336)

↓

ទាក់ទងនឹងការធ្វើកិច្ចសន្យា
ការចុះបញ្ជី ឬ លិខិតប[illegible] ជាគោលការណ៍គឺមិនមាន
ភា[illegible]ចាំបា[illegible]នោះទេ

ប៉ុន្តែ

【ករណីលើកលែង】

①កិច្ចសន្យាដោយមានការប្រគល់វត្ថុ

②ចំពោះកិច្ចសន្យាដែលធ្វើឱ្យភាគីម្ខាងមានករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ហើយភាគីម្ខាងទៀតមានករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិនោះ ត្រូវធ្វើជា<u>លិខិតយថាភូត</u>ទើបមានអានុភាព។ (CC336(2))

ឧទា:ការលក់ទិញអចលនវត្ថុ ការដូរ ប្រទានកម្ម

# ការបង្កើតកិច្ចសន្យា(CC336)

(1)កិច្ចសន្យាមានអានុភាពនៅពេលដែលសំណើ និង ស្ទីការត្រូវគ្នា។
(2)ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចផ្ទេរអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចផ្ទេរលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។

※តើអ្វីទៅជាលិខិតយថាភូត? (ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា៩ ចំណុច ក.)
→លិខិតយថាភូតដែលធ្វើឡើងដោយសារការី លិខិតដែលមន្ត្រីមានសមត្ថកិច្ចបានធ្វើឡើង

Q. តើហេតុអ្វីបានជាកិច្ចសន្យាដែលធ្វើឱ្យភាគីម្ខាងមានករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ហើយភាគីម្ខាងទៀតមានករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិនោះ ចាំបាច់ត្រូវធ្វើជា<u>លិខិតយថាភូត</u>?

【មូលហេតុ】

①ការពារអនុប្បទាយី

②ការពារអនុប្បទានិក

③មានភាពងាយស្រួលក្នុងការដោះស្រាយជម្លោះ ការពារមិនឲ្យជម្លោះកើតមានឡើង

【មូលហេតុ① ការពារអនុប្បទាយី】

ដើម្បីកុំឲ្យកម្មសិទ្ធិករនៃដីធ្វើអនុប្បទានដោយងាយៗ។ ដើម្បីកុំឲ្យកសិករជាអាទិ៍ ត្រូវគេដកហូតដីធ្លីដោយងាយស្រួល។

【មូលហេតុ② ការពារអនុប្បទានិក】

ការធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុដែលជាទ្រព្យសំខាន់ តម្រូវឲ្យខ្លឹមសារនៃកិច្ចសន្យាមានភាពត្រឹមត្រូវ។

ចំពោះកិច្ចសន្យាធ្វើលទ្ធកម្មទ្រព្យសម្បត្តិសំខាន់ ដូចជាក្នុងករណីក្រុមហ៊ុនលក់អចលនវត្ថុលក់ដីឡូតិ៍ ទៅឲ្យអ្នកទិញដែលជាអ្នកប្រើប្រាស់ធម្មតា ប្រសិនបើខនៃកិច្ចសន្យានោះមានភាពមិនត្រឹមត្រូវ សារការីអាចពន្យល់អំពីចំណុចដែលមិនត្រឹមត្រូវទាំងនោះបាន ហើយធ្វើឲ្យអ្នកទិញមានការប្រុងប្រយ័ត្ន ដែលនេះជាការការពារដល់អ្នកទិញ។

【មូលហេតុ③ មានភាពងាយស្រួលក្នុងការដោះស្រាយជម្លោះ ការពារមិនឲ្យជម្លោះកើតមានឡើង 】

នៅពេលដែលមានជម្លោះកើតឡើងទាក់ទងនឹងកិច្ចសន្យានៃការធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ បើសិនជាមានលិខិតយថាភូត នោះនឹងមានការងាយស្រួលក្នុងការដោះស្រាយជម្លោះ ហើយគេរំពឹងថា វានឹងមានមុខងារការពារកុំឲ្យជម្លោះកើតមានឡើងផងដែរ។

# លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង (CC135)

ទោះបីមានបញ្ញត្តិនៃមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) និង មាត្រា ១៣៤ (លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិប្រត្យក្ស) នៃក្រមនេះក៏ដោយ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀងមិនមានអានុភាព បើមិនបានចុះបញ្ជី ដោយយោងតាមបញ្ញត្តិនៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ស្ដីពីការចុះបញ្ជី។

# ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង

→ទោះបីជាគូភាគីនៃកិច្ចសន្យាក៏ដោយ ក៏អានុភាពនៃការផ្ទេរកម្មសិទ្ធិនឹងមិនកើតមានឡើយ បើមិនបានចុះបញ្ជី (ការចុះបញ្ជីជាលក្ខខណ្ឌអានុភាព)

※ចំពោះតែការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀងតែប៉ុណ្ណោះ

× ការបែងចែកមត៌ក
ការបែងចែកកម្មសិទ្ធិអវិភាគដោយតុលាការ
ការបែងចែកទ្រព្យសម្បត្តិដោយសារការលែងលះ

# Q. តើនៅពេលណាដែលអានុភាពនៃសំណើ និង ស្ទីការកើតឡើង?

និយមន័យនៃសំណើ និង ស្ទីការ(CC337)

(1) សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។

(2) សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ។

(3) ស្ទីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។

(4) ស្ទីការត្រូវមានអានុភាពនៅពេលដែលស្ទីការនោះបានដល់អ្នកស្នើ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្ទីការវិញដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្ទីការដល់ ឬ មុនពេលស្ទីការដល់ នោះអានុភាពនៃស្ទីការ មិនត្រូវកើតឡើយ។

# សំណើ និង ការអញ្ជើញឲ្យធ្វើសំណើ

"សំណើ" គឺជាការបង្ហាញឆន្ទៈឲ្យបង្កើតកិច្ចសន្យា ក្នុងករណីដែលការបង្ហាញឆន្ទៈរបស់ភាគីម្ខាង(ស្វីការ) ថាព្រមទទួលយកសំណើទាំងស្រុង។

"ការអញ្ជើញឲ្យធ្វើសំណើ" មិនមែនក្លាយជាសំណើតែម្តងនោះទេ គឺជាការទាក់ទាញឱ្យអ្នកដទៃធ្វើសំណើវិញ។

(ឧទា)

・ការប្រកាសរបស់ហាងលក់ម្ហូបអាហារថា "ជ្រើសរើសបុគ្គលិកបម្រើការក្នុងហាង ប្រាក់ប្រចាំម៉ោងធ្វើការ○○យ៉េន"

・ការដាក់បង្ហាញដោយបិទស្លាកតម្លៃលើទំនិញនៅផ្សារទំនើប

# Q. តើសំណើអាចដកបានដែរឬទេ?

## ករណីសិក្សា1



# ការដកសំណើមានសុពលភាព (CC337(2))

【មូលហេតុ】

ទោះបីជាទទួលស្គាល់ការដកសំណើក៏ដោយ ក៏មិនធ្វើឲ្យខាតប្រយោជន៍ដល់ភាគីដែលបានទទួលសំណើទេ ដោយសារតែគាត់មិនទាន់បានធ្វើអ្វីសោះនៅឡើយ។

# Q. តើសំណើអាចដកបានដែរឬទេ?

## ករណីសិក្សា2



# សំណើដែលគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ(CC339)

(1)ចំពោះសំណើដែលត្រូវបានធ្វើឡើងដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការរវាងគូភាគីដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព។

(2)ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ។

(3)ការដកសំណើត្រូវមានអានុភាព លុះត្រាតែការជូនដំណឹងអំពីការដកសំណើនោះបានមកដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្វីការ។

※តើ "អំឡុងពេលសមរម្យ" ជាអំឡុងពេលប៉ុន្មាន?

→អំឡុងពេលដែលចាំបាច់ទូទៅ ដើម្បីសម្រេចថាធ្វើ ឬ មិនធ្វើស្វីការចំពោះសំណើនៃកិច្ចសន្យានោះ។

មានភាពខុសគ្នាទៅតាមខ្លឹមសារនិងប្រភេទនៃកិច្ចសន្យា។

【ឧទា】

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាជាប្រតិបត្តិការស្តីពីទ្រព្យសម្បត្តិដែលសំខាន់ដូចជា មានតម្លៃថ្លៃ ឬ ជាអចលនវត្ថុជាដើម អំឡុងពេលសមរម្យនឹងមានរយៈពេលយូរ។

# Q. តើស្ទីការមានសុពលភាពទេ？

## ករណីសិក្សា3



# សំណើដែលមានការកំណត់អំឡុងពេលសម្រាប់ស្វីការ និង ការដកសំណើនោះ(CC338)

(1)សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្វីការ។ អំឡុងពេលសម្រាប់ស្វីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ បើមិនច្បាស់ថា អ្នកស្នើកំណត់ពេលផ្សេង។

(2)សំណើដែលត្រូវបានធ្វើឡើងដោយមានកំណត់អំឡុងពេលសម្រាប់ស្វីការ មិនអាចដកវិញបានទេ។

(3)ប្រសិនបើអ្នកស្នើមិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលដែលបានកំណត់នៅកថាខណ្ឌទី១ ខាងលើនេះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិនៅពេលផុតអំឡុងពេលសម្រាប់ស្វីការ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើបានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្វីការនោះ សំណើនោះក៏ត្រូវបាត់បង់អានុភាពដែរ។

# Q. តើស្វីការមានសុពលភាពទេ？

# ករណីសិក្សា4



# ការមកដល់យឺតយ៉ាវនៃស្ទីការ(CC341)

(1)ក្នុងករណីដែលការជូនដំណឹងអំពីស្ទីការ ចំពោះសំណើដែលមានអំឡុងពេលសម្រាប់ស្ទីការ មកដល់ភាគីម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្ទីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងថា ភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការនោះ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្ទីការក្នុងករណីធម្មតា នោះ អ្នកស្នើត្រូវជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះទៅអ្នកធ្វើស្ទីការ ដោយគ្មានការយឺតយ៉ាវ។ ក្នុងករណីអ្នកស្នើធ្វេសប្រហែសក្នុងការជូនដំណឹងអំពីការមកដល់ស្ទីការដោយមានការយឺតយ៉ាវនោះ ស្ទីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព។

(2)អ្នកស្នើ អាចចាត់ទុកថា ស្ទីការដែលបានមកដល់អ្នកស្នើក្រោយពេលផុតអំឡុងពេលសម្រាប់ស្ទីការ ជាសំណើថ្មី។

# Q. ចុះសុពលភាពក្នុងករណីដែលស្វីការមានបន្ថែមការកែប្រែចំពោះសំណើ?
# ករណីសិក្សា5



ក្រុមហ៊ុនAបានធ្វើសំណើនៃកិច្ចសន្យាថា "ចង់ទិញម៉ាស៊ីនធនធំដែលផលិតដោយក្រុមហ៊ុនB ចំនួន១គ្រឿងក្នុងតម្លៃ១០០លានយ៉េន ដោយយកតាមលក្ខខណ្ឌនៃកិច្ចសន្យារបស់ក្រុមហ៊ុន A" ហើយបានភ្ជាប់នូវលក្ខខណ្ឌរបស់ក្រុមហ៊ុនខ្លួនទៅជាមួយផងដែរ។

ក្រុមហ៊ុន B បានផ្តល់ចម្លើយថា " ធ្វើស្វីការទទួលយកសំណើនៃការលក់ទិញដោយតម្លៃ១០០លានយ៉េនក្នុង១គ្រឿង ដោយយកតាមលក្ខខណ្ឌនៃកិច្ចសន្យារបស់ក្រុមហ៊ុន B" ហើយបានភ្ជាប់នូវលក្ខខណ្ឌរបស់ក្រុមហ៊ុនខ្លួនទៅជាមួយផងដែរ។

※ ទាំងលក្ខខណ្ឌរបស់ក្រុមហ៊ុនA និង ទាំងលក្ខខណ្ឌរបស់ក្រុមហ៊ុន B សុទ្ធតែជាខ្លឹមសារដែលមានប្រយោជន៍សម្រាប់ក្រុមហ៊ុនរៀងៗខ្លួន ប៉ុន្តែលក្ខខណ្ឌនៃកិច្ចសន្យារវាងក្រុមហ៊ុនទាំង២នេះ មានលក្ខណៈមិនស៊ីគ្នាសោះ។

ក្នុងករណីនេះ

①តើកិច្ចសន្យានឹងត្រូវបង្កើតឡើងទេ?

②ឧបមាថាកិច្ចសន្យានឹងត្រូវបង្កើតឡើង តើលក្ខខណ្ឌនៃកិច្ចសន្យាត្រូវធ្វើឡើងដោយផ្អែកលើលក្ខខណ្ឌរបស់ក្រុមហ៊ុនមួយណា?

# ស្ទីការដោយមានការបន្ថែមការកែប្រែ(CC342)

(1) ស្ទីការដែលអ្នកធ្វើស្ទីការបានដាក់លក្ខខណ្ឌលើសំណើ ឬ កែប្រែសារធាតុផ្សេងនៃសំណើ មិនត្រូវក្លាយជាស្ទីការសុពល តែស្ទីការនោះមានអានុភាពជាសំណើថ្មី។ កិច្ចសន្យាត្រូវកើតឡើងនៅពេលដែលអ្នកធ្វើសំណើដើម ធ្វើស្ទីការចំពោះសំណើថ្មីនោះ។
(2) ប្រសិនបើលក្ខខណ្ឌ ឬ ការកែប្រែដែលភ្ជាប់ជាមួយនឹងស្ទីការ មិនធ្វើឲ្យមានការកែប្រែសារធាតុនៃសំណើទេ ស្ទីការនោះមានសុពលភាព លុះត្រាតែអ្នកស្នើមិនតវ៉ាភ្លាម។ អត្ថន័យនៃកិច្ចសន្យាដែលត្រូវកើតឡើងដោយស្ទីការនោះ ត្រូវទៅតាមអត្ថន័យនៃស្ទីការ លុះត្រាតែអ្នកស្នើដែលបានទទួលស្ទីការមិនតវ៉ាភ្លាមៗទេ។

ដោយសារតែខ្លឹមសារនៃលក្ខខណ្ឌរបស់ក្រុមហ៊ុនទាំងពីរខុសគ្នាឆ្ងាយ ដូច្នេះ ជាគោលការណ៍ ផ្អែកតាមមាត្រា 342 កថាខណ្ឌទី1 កិច្ចសន្យាមិនកើតឡើងនោះទេ។

ប៉ុន្តែ

នៅក្នុងប្រតិបត្តិការជាក់ស្តែងវិញ មានករណីមិនតិចទេដែលគេចាប់ផ្តើមអនុវត្តកិច្ចសន្យាឱ្យតែមានការព្រមព្រៀងអំពីលក្ខខណ្ឌចម្បងដូចជា កម្មវត្ថុនៃកិច្ចសន្យា ឬ ថ្លៃលក់ជាដើម។

【ចំពោះករណីសិក្សាខាងលើនេះ】

សំបុត្រស្តីពីស្វ័ការរបស់ក្រុមហ៊ុនB ត្រូវបានចាត់ទុកថាគឺជាសំណើថ្មី ហើយប្រសិនបើក្រុមហ៊ុនA បានរៀបចំសម្រាប់ការទទួលយកទំនិញ និងឈានទៅដល់នីតិវិធីនៃការបង់ប្រាក់ ដែលជាសកម្មភាពឆ្លើយតបទៅនឹងសំបុត្ររបស់ក្រុមហ៊ុន B ដូច្នេះ តាមរយៈសកម្មភាពដែលបានអនុវត្តនេះ នឹងត្រូវបានចាត់ទុកថា មានស្វ័ការដោយតុណ្ហីភាព។ ហេតុនេះ កិច្ចសន្យាត្រូវបានបង្កើត(CC342(1))។

ខ្លឹមសារនៃកិច្ចសន្យាលក់ទិញនឹងត្រូវយកតាមលក្ខខណ្ឌក្នុងក្រុមហ៊ុនB(មាត្រាដដែល (2))។

# 2 ការលុបចោលកិច្ចសន្យា

※ក្នុងសិក្ខាសាលាលើកនេះនឹងលើកឡើងជាពិសេសអំពី ការបង្ហាញឆន្ទៈមានវិការៈ ដែលមាននៅក្នុងការលុបចោលកិច្ចសន្យាផងដែរ។

ក្រៅពីនេះ នៅក្នុងក្រមរដ្ឋប្បវេណីប្រទេសកម្ពុជា ក៏មានបញ្ញត្តិស្ដីពីករណីដែលធ្វើការលុបចោលនូវសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ឬ សមត្ថភាពក្នុងការធ្វើសកម្មភាព (យោង:CC14, 18, 26, 30)។

# Q. តើអ្វីទៅជាការលុបចោលកិច្ចសន្យា？

កិច្ចសន្យាលក់ទិញដីAត្រូវបានបង្កើតឡើងរវាង អ្នកលក់X និង អ្នកទិញY។



# គោលគំនិតនៃការលុបចោល

នៅពេលដែលកិច្ចសន្យាលក់ទិញបានបង្កើតឡើង ភាគីត្រូវមានករណីយកិច្ចចំពោះភាគីម្ខាងទៀតទៅវិញទៅមក។

ដូច្នេះ ភាគីទាំងសងខាងត្រូវតែអនុវត្តករណីយកិច្ចរបស់ខ្លួន។



# គោលគំនិតនៃការលុបចោល

ឧទាហរណ៍៖ នៅក្រោយពេលចុះកិច្ចសន្យា ទោះបីជាអ្នកទិញY បានគិតថា "ប្រសិនបើមិនទិញដី ហើយទិញរថយន្ត Ferrari ប្រហែលជាប្រសើរជាង។" ក៏ដោយ ក៏ត្រូវតែអនុវត្តករណីយកិច្ចបង់ប្រាក់ដោយផ្អែកលើកិច្ចសន្យាលក់ទិញនោះដែរ។

ប៉ុន្តែ ប្រសិនបើការបង្ហាញឆន្ទៈរបស់ភាគីមានវិការៈ ការទទួលស្គាល់នូវអានុភាពនៃការង្ហាញឆន្ទៈ គឺមិនត្រឹមត្រូវទេ ដូច្នេះ មានករណីត្រឹមត្រូវដែលអាចសង្គ្រោះភាគីឲ្យរួចផុតពីករណីយកិច្ចដែលកើតចេញពីកិច្ចសន្យានោះ។

ហេតុដូច្នេះហើយ ទើបមានប្រព័ន្ធនៃការលុបចោលនូវកិច្ចសន្យា ដើម្បីការពារភាគីដែលបានបង្ហាញឆន្ទៈមានវិការៈ។




ក្នុងករណីដែលអ្នកទិញY មិនទាន់បានបង់ប្រាក់ អ្នកទិញY នឹងត្រូវបានរួចផុតពីករណីយកិច្ចបង់ប្រាក់តាមរយៈការលុបចោលនូវកិច្ចសន្យា(CC358(2))។




អ្នកទិញY អាចយកប្រាក់ត្រឡប់មកវិញបានតាមរយៈការលុបចោលនូវកិច្ចសន្យា ក្នុងករណីដែលខ្លួនបានបង់ប្រាក់រួចរាល់ (ការទាមទារឲ្យសងតាមសេចក្ដីចម្រើនដោយឥតហេតុ CC736)។

ហេតុនេះ តាមរយៈការលុបចោលនូវកិច្ចសន្យា នឹងអាច មានលទ្ធភាព ២យ៉ាងដូចខាងក្រោម៖

① បានរួចផុតពីករណីយកិច្ចដែលបានកើតចេញពីកិច្ចសន្យា

② យកមកវិញនូវវត្ថុដែលបានប្រគល់ ឬ ប្រាក់ ដែលជាការអនុវត្តករណីយកិច្ចដែលបានកើតចេញពីកិច្ចសន្យា

③ ប៉ុន្តែ ប្រសិនបើមានវត្ថុដែលបានទទួលពីភាគីម្ខាងទៀត ដែលជាការអនុវត្តករណីយកិច្ចដែលបានកើតចេញពីកិច្ចសន្យា ត្រូវតែសងត្រឡប់ទៅភាគីម្ខាងទៀតវិញ

ដូច្នេះ តើនៅក្នុងករណីបែបណាទើប អាចទទួលស្គាល់ការលុបចោលបាន?

# ករណីដែលអាចលុបចោលកិច្ចសន្យាបាន

① ការភាន់ច្រឡំ(CC345(1),346)
② ការឆបោក(CC345(2),347)
③ ការគម្រាមកំហែង(CC345(2),350)
④ ព័ត៌មានមិនពិត(CC345(2),348)
⑤ អំពើកេងយកចំណេញហួសហេតុ (CC345(3),351)
⑥ ការរំលោភបំពានលើស្ថានភាព (CC349)

# ករណីដែលអាចលុបចោលកិច្ចសន្យាបាន

① <u>ការភាន់ច្រឡំ</u>(CC345(1),346)
② ការឆបោក(CC345(2),347)
③ ការគម្រាមកំហែង(CC345(2),350)
④ ព័ត៌មានមិនពិត(CC345(2),348)
⑤ អំពើកេងយកចំណេញហួសហេតុ (CC345(3),351)
⑥ ការរំលោភបំពានលើស្ថានភាព (CC349)

# ករណីសិក្សា1 : តើYអាចលុបចោលកិច្ចសន្យាបានទេ ?



# ការលុបចោលដោយសារការភាន់ច្រឡំ
(CC346(1))

ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

【លក្ខខណ្ឌ】

①អ្នកបង្ហាញឆន្ទៈ ៖ ភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា

②ភាគីម្ខាងទៀត ៖ អាចដឹងអំពីការភាន់ច្រឡំ

# ការលុបចោលដោយសារការភាន់ច្រឡំ
(CC346(1))

①អ្នកបង្ហាញឆន្ទៈ ៖ "ចំណុចសំខាន់ៗនៃកិច្ចសន្យា"គឺជាអ្វី？

→ត្រូវកំណត់ដោយសត្យានុម័តទៅតាមប្រភេទនៃកិច្ចសន្យា និង កាលៈទេសៈជាក់ស្តែងផ្សេងទៀត។

(ឧទា)ករណីកិច្ចសន្យាលក់ទិញ

ការយល់ច្រឡំអ្នកលក់ ឬ អ្នកទិញ → មិនមែនជាចំណុចសំខាន់

ការយល់ច្រឡំអំពីកម្មវត្ថុ → ចំណុចសំខាន់

# ការលុបចោលដោយសារការភាន់ច្រឡំ
(CC346(1))

②ភាគីម្ខាងទៀត ៖ អាចដឹងអំពីការភាន់ច្រឡំ

ដឹងអំពីការភាន់ច្រឡំនោះ

ឬ

អាចដឹងអំពីការភាន់ច្រឡំនោះ

មូលហេតុ៖ ការពារភាគីម្ខាងទៀត សុវត្ថិភាពនៃប្រតិបត្តិការជំនួញ (ដើម្បីកុំឲ្យភាគីម្ខាងទៀត ឬ តតិយជន ទទួលរងការខូចខាតដែលមិនអាចគិតទុកជាមុនបាន ហើយប្រតិបត្តិការជំនួញអាចប្រព្រឹត្តទៅបានដោយរលូន)

# ការលុបចោលដោយសារការភាន់ច្រឡំ
(CC346(1))

ករណីសិក្សា1 : តើYអាចលុបចោលកិច្ចសន្យាបានដែរឬទេ ?

តើ X បានដឹងអំពីការភាន់ច្រឡំរបស់ Y ដែរឬទេ? ប្រសិនបើ X អាចដឹង Yអាចលុបចោលកិច្ចសន្យាបាន។

# ករណីសិក្សា2៖Yអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



ភ្នំដែលមានព្រៃឈើA

ថ្ងៃទី១ ខែមករា ឆ្នាំ២០១៧, ខ្ញុំបានលក់ភ្នំដែលមានព្រៃឈើA ឲ្យទៅY ក្នុងតម្លៃ១ម៉ឺនដុល្លារ ដូច្នេះ Y បង់ប្រាក់១ម៉ឺនដុល្លារនោះមក។



X



Y

<u>ដើម្បីកាប់ព្រៃឈើ ទើបខ្ញុំទិញភ្នំដែលមានព្រៃឈើA</u> ប៉ុន្តែ តាមពិតទៅ ខ្ញុំមិនបានដឹងថា តំបន់នោះជាតំបន់ដែលបានហាមមិនឱ្យកាប់ដើមឈើទេ។ ខ្ញុំមិនចង់បង់ប្រាក់ទេ។

# ការលុបចោលដោយសារការភាន់ច្រឡំ
(CC346(2))

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ (ភាន់ច្រឡំអំពីមូលហេតុ(បំណង)) ។

# ការលុបចោលដោយសារការភាន់ច្រឡំ (CC346(2))

ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យា មានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬ ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា បើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះ និង ការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះ ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

【លក្ខខណ្ឌ】

① ការភាន់ច្រឡំអំពីមូលហេតុរបស់អ្នកបង្ហាញឆន្ទៈ
 i ចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់
 ii ចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា

② ភាពសំខាន់នៃមូលហេតុ និង ភាពដែលអាចដឹងអំពីការភាន់ច្រឡំ (ភាគីម្ខាងទៀត)

# ការលុបចោលដោយសារការភាន់ច្រឡំ（CC346(２)）

※តើឧទាហរណ៍នេះត្រូវនឹងភាពសំខាន់នៃមូលហេតុរបស់កិច្ចសន្យាទេ?

(ឧទា) ពណ៌របស់រថយន្តនៅក្នុងកិច្ចសន្យាលក់ទិញរថយន្ត

ដើម្បីប្រើប្រាស់សម្រាប់ការងារ អ្នកទិញY បានដើររកមើលរថយន្តពណ៌ខ្មៅ ហើយបានចុះកិច្ចសន្យាលក់ទិញរថយន្តដែលមានពណ៌ក្រហមជាមួយនឹងអ្នកលក់X ដោយគិតថា រថយន្តដែលខ្លួនបានទិញនោះ ជារថយន្តពណ៌ខ្មៅទេ។

X អាចដឹងថា  Y បានគិតថា ពណ៌រថយន្តសំខាន់ណាស់ ហើយយល់ច្រឡំថាពណ៌រថយន្តដែលបានចុះក្នុងកិច្ចសន្យាជាពណ៌ខ្មៅមិនមែនជាពណ៌ក្រហម ។

# ការលុបចោលដោយសារការភាន់ច្រឡំ
（CC346(2)）

ករណីសិក្សា 2：តើYអាចលុបចោលកិច្ចសន្យាបានដែរទេ?

① Yមានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា

② Xអាចដឹងអំពីការភាន់ច្រឡំនោះ ហើយXក៏មានលទ្ធភាពអាចដឹងថា មូលហេតុនៃការធ្វើកិច្ចសន្យានោះ មានសារៈសំខាន់ណាស់ចំពោះY។

③ Y អាចលុបចោលកិច្ចសន្យានោះបាន តែក្នុងករណីដែលបានបញ្ជាក់ភស្តុតាងអំពីការភាន់ច្រឡំនោះប៉ុណ្ណោះ។

# ករណីសិក្សា3 : Yអាចលុបចោលកិច្ចសន្យាបានដែរឬទេ ?



ភ្នំដែលមានព្រៃឈើA



X

ថ្ងៃទី១ ខែមករា ឆ្នាំ២០១៧, ខ្ញុំបានលក់ភ្នំដែលមានព្រៃឈើA ឲ្យទៅY ក្នុងតម្លៃ១ម៉ឺនដុល្លារ ដូច្នេះ Y បង់ប្រាក់១ម៉ឺនដុល្លារនោះមក។



Y

<u>ដើម្បីកាប់ព្រៃឈើ ទើបខ្ញុំទិញភ្នំដែលមានព្រៃឈើA</u> ប៉ុន្តែតាមពិតទៅ ខ្ញុំមិនបានដឹងថា តំបន់នោះជាតំបន់ដែលបានហាមមិនឱ្យកាប់ដើមឈើទេ។ ខ្ញុំមិនចង់បង់ប្រាក់ទេ។

ខ្ញុំមិនបានដឹងថា ភ្នំដែលមានព្រៃឈើA គឺជាតំបន់ដែលបានហាមមិនឱ្យកាប់ដើមឈើទេ។

# ការភាន់ច្រឡំរួម (CC346(3))

ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា ឬ ចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ ឬ ចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យា ទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរ ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

【លក្ខខណ្ឌ】

ក្នុងករណីដែលភាគីទាំងពីរនៃកិច្ចសន្យាភាន់ច្រឡំអំពី ៖

- i ចំណុចសំខាន់ៗនៃកិច្ចសន្យា
- ii ចំណុចនៃកិច្ចសន្យាដែលយល់ឃើញថាសំខាន់
- iii ភាគីទាំងសងខាងបានយល់ច្រឡំអំពីចំណុចដែលបានយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យានោះ

# ការលុបចោលដោយសារការភាន់ច្រឡំ
(CC346(3))

ករណីសិក្សា3៖តើ Yអាចលុបចោលកិច្ចសន្យាបានដែរឬទេ?

ស្តីពីចំណុចសំខាន់ៗនៃកិច្ចសន្យា ក្នុងករណីដែល X និងY មានការភាន់ច្រឡំទាំងសងខាង ហើយទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយ ក៏Yអាចលុបចោលនូវកិច្ចសន្យាបានដែរ។

※ កម្មវត្ថុនៃការភាន់ច្រឡំនេះ មិនចាំបាច់បែងចែកថា តើវាជាផ្នែកសំខាន់ដែលមានលក្ខណៈវត្ថុវិស័យ(objective) ឬ ក៏ជាផ្នែកសំខាន់ដែលមានលក្ខណៈអត្តវិស័យ (subjective) ឬក៏ជាផ្នែកពាក់ព័ន្ធនឹងមូលហេតុនៃការបង្កើតកិច្ចសន្យានោះទេ។

# ករណីសិក្សា4: តើXអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



# ការលុបចោលដោយសារការភាន់ច្រឡំ
(CC346(4))

ការលុបចោលនូវកិច្ចសន្យាដោយសារការភាន់ច្រឡំ ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិន បើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការភាន់ច្រឡំ មិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ។

※ "សុចរិត ហើយគ្មានកំហុស"ជាអ្វី?
→ការមិនដឹងថាជាការបង្ហាញឆន្ទៈដោយសារការភាន់ច្រឡំ ហើយគ្មានកំហុសអំពីការមិនបានដឹងនោះ។

# ការលុបចោលដោយសារការភាន់ច្រឡំ
(CC346(4))

ករណីសិក្សា4: តើXអាចលុបចោលកិច្ចសន្យាបានដែរឬទេ?

↓

ក្នុងករណីដែល Z បានដឹង ឬមានកំហុសក្នុងការមិនបានដឹងអំពីការភាន់ច្រឡំរបស់X នោះXអាចអះអាងអំពីការលុបចោលកិច្ចសន្យាបាន។

# ករណីដែលអាចលុបចោលកិច្ចសន្យាបាន

① ការភាន់ច្រឡំ(CC345(1),346)

② <u>ការឆបោក</u>(CC345(2),347)

③ ការគម្រាមកំហែង(CC345(2),350)

④ ព័ត៌មានមិនពិត(CC345(2),348)

⑤ អំពើកេងយកចំណេញហួសហេតុ (CC345(3),351)

⑥ ការរំលោភបំពានលើស្ថានភាព(CC349)

# ករណីសិក្សា5៖តើYអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



ដីA



X

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដីA ឲ្យទៅY ក្នុងតម្លៃ១ម៉ឺនដុល្លារ ដូច្នេះ Y ត្រូវបង់ប្រាក់ ១ម៉ឺនដុល្លារនោះមក។



Y

ខ្ញុំបានទិញដីA ពីX ដោយសារតែ W **ដែលជាមិត្តសំឡាញ់របស់X** បាននិយាយថា ដីនោះគឺជាដីដែលអាចដាំដុះដំណាំបានល្អ។ ប៉ុន្តែ តាមការពិត W បានកុហក ហើយដីនោះគឺជាដីដែលមានជាតិពុលខ្លាំង ដូច្នេះ ខ្ញុំមិនចង់បង់ប្រាក់ទេ។

# ការលុបចោលដោយសារការឆបោក (CC347(1))

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

# ការលុបចោលដោយសារការឆបោក (CC347(1))

បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

※【លក្ខខណ្ឌ】

①ភាគីម្ខាងទៀត ៖ បានបង្ហាញព័ត៌មានមិនពិតដោយទុច្ចរិត (បានបោក)។

②អ្នកបង្ហាញឆន្ទៈ៖ បានបង្ហាញឆន្ទៈខុសពីឆន្ទៈពិតដោយសារការឆបោក។

# ការលុបចោលដោយសារការឆបោក (CC347(2))

ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យា ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ លុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះ បានដឹង ឬ អាចដឹងអំពីការឆបោកនោះ។

# ការលុបចោលដោយសារការឆបោក
(CC347(2))

ករណីសិក្សា5៖តើYអាចលុបចោលកិច្ចសន្យាបានដែរឬទេ?

Y អាចលុបចោលកិច្ចសន្យាបានតែក្នុងករណីដែល X បានដឹង ឬ អាចដឹងអំពីការឆបោករបស់ W ប៉ុណ្ណោះ។

# ករណីសិក្សា6៖តើXអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



# ការលុបចោលដោយសារការឆបោក (CC347(3))

ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការបោក មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។

# ការលុបចោលដោយសារការឆបោក
(CC347(3))

ការលុបចោលនូវកិច្ចសន្យាដោយការឆបោក ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីការបោក មិនអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។

※តើអ្វីទៅជា "សុចរិត ហើយគ្មានកំហុស" ?
→ ការមិនបានដឹងថា ជាការបង្ហាញឆន្ទៈដោយសារការឆបោក ហើយគ្មានកំហុសក្នុងការមិនបានដឹងនោះ។

# ការលុបចោលដោយសារការឆបោក (CC347(3))

ករណីសិក្សា6៖តើXអាចលុបចោលកិច្ចសន្យាបានដែរឬទេ?

ក្នុងករណីដែល Zមិនបានដឹងអំពីការឆបោករបស់Y ហើយមិនមានកំហុសអំពីការមិនបានដឹងនោះ  X មិនអាចលុបចោលនូវកិច្ចសន្យាបានទេ។

# ករណីដែលអាចលុបចោលកិច្ចសន្យាបាន

① ការភាន់ច្រឡំ(CC345(1),346)

② ការឆបោក(CC345(2),347)

③ <u>ការគម្រាមកំហែង</u>(CC345(2),350)

④ ព័ត៌មានមិនពិត(CC345(2),348)

⑤ អំពើកេងយកចំណេញហួសហេតុ (CC345(3),351)

⑥ ការរំលោភបំពានលើស្ថានភាព(CC349)

# ករណីសិក្សា7៖តើYអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



ដីA



នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដីA ឲ្យទៅY ក្នុងតម្លៃ១ម៉ឺនដុល្លារ ដូច្នេះ Y ត្រូវបង់ប្រាក់ ១ម៉ឺនដុល្លារនោះមក។

X



Y

Xបាននិយាយថានឹងធ្វើឲ្យខ្ញុំស្គាល់រសជាតិនៃការឈឺចាប់ ប្រសិនបើខ្ញុំមិនទិញដីAពីX ហេតុនេះ ខ្ញុំត្រូវបានបង្ខំឲ្យចុះកិច្ចសន្យាតែប៉ុណ្ណោះ ដូច្នេះ ខ្ញុំមិនចង់បង់ប្រាក់នោះទេ។

# ការលុបចោលដោយសារការគម្រាមកំហែង (CC350)

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

# ការលុបចោលដោយសារការគម្រាមកំហែង (CC350)

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

※【លក្ខខណ្ឌ】

①លើកឡើងនូវគំនិតបង្ករការរងគ្រោះទៅភាគី
②ធ្វើឲ្យភាគីភ័យក្តុកក្តួល
③ដោយសារសកម្មភាពទាំងនេះទើបធ្វើឲ្យភាគីបង្ហាញឆន្ទៈ

# ការលុបចោលដោយសារការគម្រាមកំហែង (CC350)

ករណីសិក្សា7 : តើYអាចលុបចោលកិច្ចសន្យាបានដែរឬទេ?

Yអាចលុបចោលកិច្ចសន្យាបាន ដោយសារមូលហេតុការគម្រាមកំហែងរបស់X។

# ករណីសិក្សា៨ៈតើXអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



# ការលុបចោលដោយសារការគម្រាមកំហែង
(CC350)

ករណីសិក្សា៨ : តើXអាចលុបចោលកិច្ចសន្យាបានដែរឬទេ?

Xអាចលុបចោលកិច្ចសន្យាដោយមូលហេតុនៃការគម្រាមកំហែងរបស់Yបាន ទោះបីជា Z សុចរិតហើយគ្មានកំហុសក្នុងការគម្រាមកំហែងរបស់Yក៏ដោយ។

※ ដោយសារភាពចាំបាច់ដែលត្រូវការពារអ្នកបង្ហាញឆន្ទៈដោយសារការគម្រាមកំហែង ខ្លាំងជាងការឆបោក  ហេតុនេះ ពុំមានបញ្ញត្តិដែលការពារតតិយជនដូចនៅក្នុងមាត្រាCC347(3)ឡើយ។

# ករណីដែលអាចលុបចោលកិច្ចសន្យាបាន

① ការភាន់ច្រឡំ(CC345(1),346)
② ការឆបោក(CC345(2),347)
③ ការគម្រាមកំហែង(CC345(2),350)
④ <u>ព័ត៌មានមិនពិត</u>(CC345(2),348)
⑤ អំពើកេងយកចំណេញហួសហេតុ (CC345(3),351)
⑥ ការរំលោភបំពានលើស្ថានភាព(CC349)

# ករណីសិក្សា១៖តើYអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



ដីA

ថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដីA ឲ្យទៅY ក្នុងតម្លៃ១ម៉ឺនដុល្លារ ដូច្នេះ Y ត្រូវបង់ប្រាក់១ម៉ឺនដុល្លារនោះមក។





ខ្ញុំបានទិញដីA ពីX ដោយសារតែឮថាដីនោះជាដីដែលអាចដាំដំណាំបានល្អ  ប៉ុន្តែ ក្រោយមក ខ្ញុំបានដឹងថា ដីនោះមានជាតិពុលខ្លាំង ហេតុនេះ ខ្ញុំមិនចង់បង់ប្រាក់ឡើយ។

X

Y

ការលុបចោលដោយការឆបោក?

→ មានភាពចាំបាច់នៃការបង្ហាញព័ត៌មានមិនពិតដោយទុច្ចរិតរបស់ភាគីម្ខាង

ការលុបចោលដោយសារការភាន់ច្រឡំ ?

→ ចាំបាច់ត្រូវមានលក្ខខណ្ឌ
- អ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ
- +
- ផ្នែកសំខាន់នៃកិច្ចសន្យា
- +
- លទ្ធភាពដែលអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀត

# ការលុបចោលដោយសារការបង្ហាញព័ត៌មានមិនពិត(CC348(1))

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

# ការលុបចោលដោយសារការបង្ហាញព័ត៌មានមិនពិត (CC348(1))

នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិត ប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

※ទោះបីជាគ្មានភាពទុច្ចរិតក៏ដោយ ក៏ត្រូវនឹងលក្ខខណ្ឌនៃមាត្រានេះដែរ។

យោង ៖ ក្នុងករណីទុច្ចរិត គឺជា "ការឆបោក"

# ការលុបចោលដោយសារការបង្ហាញព័ត៌មានមិនពិត(CC348(1))

ករណីសិក្សា9: តើYអាចលុបចោលកិច្ចសន្យាបានទេ?

Y អាចលុបចោលកិច្ចសន្យាបាន ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយផ្អែកលើព័ត៌មានមិនពិតដែលបានផ្ដល់ដោយX។

# ករណីសិក្សា10:តើXអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



# ការលុបចោលដោយសារការបញ្ញាញព័ត៌មានមិនពិត(CC348(3))

ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។

※ "សុចរិតហើយគ្មានកំហុស" ជាអ្វី?

→ការមិនបានដឹងអំពីព័ត៌មានមិនពិត ហើយគ្មានកំហុសអំពីការមិនបានដឹង។

# ការលុបចោលដោយសារការបង្ហាញព័ត៌មានមិនពិត(CC348(3))

ករណីសិក្សា10:តើXអាចលុបចោលកិច្ចសន្យាបានដែរឬទេ?

ក្នុងករណីដែល Z បានដឹង ឬ មានកំហុសអំពីការមិនបានដឹងនូវការបង្ហាញព័ត៌មានមិនពិតដែលបានផ្តល់ដោយY នោះX អាចអះអាងនូវការលុបចោលបាន។

# ករណីដែលអាចលុបចោលកិច្ចសន្យាបាន

① ការភាន់ច្រឡំ(CC345(1),346)

② ការឆបោក(CC345(2),347)

③ ការគម្រាមកំហែង(CC345(2),350)

④ ព័ត៌មានមិនពិត(CC345(2),348)

⑤ អំពើកេងយកចំណេញហួសហេតុ
(CC345(3),351)

⑥ ការរំលោភបំពានលើស្ថានភាព(CC349)

# ករណីសិក្សា11:តើYអាចលុបចោលកិច្ចសន្យាបានដែរឬទេ?



ដីA



នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដីA ឲ្យទៅY ក្នុងតម្លៃ១០ម៉ឺនដុល្លារ ដូច្នេះ Y ត្រូវបង់ប្រាក់១០ម៉ឺនដុល្លារនោះមក។

X



Xគឺជាអ្នកជំនួញអចលនវត្ថុដែលដឹងច្បាស់លាស់អំពីតម្លៃដី។ ខ្ញុំមិនដឹងច្បាស់លាស់អំពីដីនោះទេ ហើយនេះជាលើកដំបូងដែលខ្ញុំបានទិញដី។ ឥឡូវនេះ ខ្ញុំបានដឹងថា តាមពិត ដីនោះមានតម្លៃត្រឹមតែខ្ទង់១ម៉ឺនដុល្លារប៉ុណ្ណោះ ដូច្នេះ ខ្ញុំមិនចង់បង់ប្រាក់ទេ។

Y

# ការលុបចោលដោយសារអំពើគេចយកចំណេញហួសហេតុ(CC351)

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

# ការលុបចោលដោយសារអំពើកេងយកចំណេញហួសហេតុ(CC351)

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយបានកេងយកចំណេញសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

※តើមូលដ្ឋាននៃការសម្រេចអំពី "ការកេងយកចំណេញសន្ធឹកសន្ធាប់" ជាអ្វី?

→ដោយសារតែអត្ថន័យនៃពាក្យនេះ មានភាពខុសគ្នាតាមពេលវេលា និងស្ថានភាព ដូច្នេះ មានភាពចាំបាច់ក្នុងការសម្រេចបន្ថែមអំពីអត្ថន័យឲ្យបានកាន់តែច្រើន។

# ករណីដែលអាចលុបចោលកិច្ចសន្យាបាន

① ការភាន់ច្រឡំ(CC345(1),346)
② ការឆបោក(CC345(2),347)
③ ការគម្រាមកំហែង(CC345(2),350)
④ ព័ត៌មានមិនពិត(CC345(2),348)
⑤ អំពើកេងយកចំណេញហួសហេតុ (CC345(3),351)
⑥ ការរំលោភបំពានលើស្ថានភាព(CC349)

# ករណីសិក្សា12:តើYអាចលុបចោលកិច្ចសន្យាបានឬទេ?



ដីA

ថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដីA ឲ្យទៅY ក្នុងតម្លៃ១ម៉ឺនដុល្លារ ដូច្នេះ Y បង់ប្រាក់១ម៉ឺនដុល្លារនោះមក។



X



Y

តាមពិតទៅ ខ្ញុំមិនត្រូវការដីអ្វីនោះទេ ប៉ុន្តែ X គឺជាប្រធានក្រុមហ៊ុនដែលប្អូនប្រុសខ្ញុំកំពុងធ្វើការ ហើយខ្ញុំបានគិតថា បើបដិសេធ ប្អូនប្រុសខ្ញុំប្រហែលជានឹងត្រូវបណ្តេញចេញពីការងារ ហើយដោយសារតែគ្មានវិធីដោះស្រាយ ខ្ញុំក៏បានចុះកិច្ចសន្យា ដូច្នេះ ខ្ញុំមិនចង់បង់ប្រាក់ទេ។

# ការលុបចោលដោយសារការរំលោភបំពានលើស្ថានភាព (CC349(1))

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈដែលខ្លួនមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

# ការលុបចោលដោយសារការរំលោភបំពានលើស្ថានភាព(CC349(1))

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើដោយមិនត្រឹមត្រូវនូវឋានៈដែលខ្លួនមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

※ "ការកេងយកចំណេញសន្ធឹកសន្ធាប់" មិនមែនជាលក្ខខណ្ឌទេ។

→ទោះបីជាការលក់ត្រូវបានធ្វើឡើងក្នុងតម្លៃសមរម្យក៏ដោយ ក្នុងករណីដែលធ្វើការវាយតម្លៃឃើញថា កិច្ចសន្យាអំពីទំនិញ ឬ សេវាដែលមិនត្រូវការបានធ្វើឡើងដោយសារការរំលោភបំពានលើស្ថានភាព ការលុបចោលនូវកិច្ចសន្យានឹងត្រូវបានទទួលស្គាល់។

# ការលុបចោលដោយសារការរំលោភបំពានលើស្ថានភាព(CC349(2))

ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលជាជន<u>សុចរិត ហើយគ្មានកំហុស</u>អំពីការរំលោភបំពានលើស្ថានភាពបានឡើយ។

※តើ "សុចរិតហើយគ្មានកំហុស"ជាអ្វី?

→ការមិនបានដឹងអំពីការរំលោភបំពានលើស្ថានភាព ហើយមិនមានកំហុសអំពីការមិនបានដឹងនោះ។

# អ្នកដែលមានសិទ្ធិលុបចោល？

→ការអះអាងអំពីការលុបចោល គឺមានតែ「អ្នកមានសិទ្ធិលុបចោល」ប៉ុណ្ណោះដែលអាចធ្វើបាន។

មូលហេតុ ៖ នេះគឺជាប្រព័ន្ធសម្រាប់ការពារដល់ភាគីដែលបង្ហាញឆន្ទៈមានវិការៈ ហេតុនេះ យើងទទួលស្គាល់ការលុបចោលចំពោះតែបុគ្គលនេះ គឺជាការគ្រប់គ្រាន់។

អ្នកបង្ហាញឆន្ទៈមានវិការៈ (cc359) អាចលុបចោលបានដោយមូលហេតុការបង្ហាញឆន្ទៈមានវិការៈ (cc346~351)។

# ករណីសិក្សា



ដីA



ថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដី A ទៅ Y ក្នុងតម្លៃ ១០០០០$ ហេតុនេះ Y ត្រូវបង់ប្រាក់ថ្លៃដី ១០០០០$។

X



Y

Y បានទិញដី A ក្នុងតម្លៃ ១០០០០$ ដោយសារពួគាត់ថា ដី A អាចដាំដុះបានល្អ។ ប៉ុន្តែ X បានកុហក ហើយដីនោះមានជាតិពុលខ្លាំង។

# អ្នកមានសិទ្ធិលុបចោល

Q:ក្នុងករណីសិក្សានេះ តើអ្នកណាជាអ្នកមានសិទ្ធិលុបចោល?

អ្នកបោកប្រាស់ X ?

Z ដែលជាមិត្តរបស់Y ?

A:「អ្នកដែលបង្ហាញឆន្ទៈមានវិការៈ」(=អ្នកមានសិទ្ធិលុបចោល)

Y ដែលត្រូវគេបោកប្រាស់

# វិធីលុបចោល

តើ Y គួរតែលុបចោលដោយរបៀបណាទើបល្អ?

តើ Y ត្រូវការសាលក្រម/សាលដីកាដែរ ឬទេ?

# វិធីលុបចោល

## កាលពីមុន តម្រូវឲ្យមានសាលក្រម/សាលដីកា។

「 ក្រឹត្យ~ច្បាប់លេខ ៣៨ ស្ដីពី កិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា 」

ក្នុងករណីមោឃភាពនៃកិច្ចសន្យា បណ្ដាលមកពីមូលហេតុអសមត្ថភាព ការភ័ន្តច្រឡំ ហឹង្សា ឬ ការបន្លំបោកប្រាស់ ការសុំមោឃភាពនៃកិច្ចសន្យានេះអាចនឹងធ្វើឡើងដោយភាគីរងគ្រោះ...។

ភាគីរងគ្រោះ...អាចសុំប្ដឹងមោឃភាពនៃកិច្ចសន្យានោះ ក្នុងរយៈពេល ១២ ខែយ៉ាងយូរ។

# វិធីលុបចោល

ប៉ុន្តែ

**យោងតាម មាត្រា ៧៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ក្រឹត្យច្បាប់ លេខ ៣៨ ត្រូវបាននិរាករណ៍**

↓

នៅក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ដើម្បី
「 លុបចោល 」គឺ「 **មិនចាំបាច់** 」
មានសាលក្រម/សាលដីកាទេ

# វិធីលុបចោល

→ គ្រាន់តែបង្ហាញឆន្ទៈថា "លុបចោល" ប៉ុណ្ណោះ (CC360)

→វិធីបង្ហាញឆន្ទៈបែបណាក៏បាន

ឧទា : និយាយគ្នាចំពោះមុខ ឬតាមទូរស័ព្ទ ឬតាមលិខិត ឬតាមអ៊ីម៉ែល ជាដើម

ប៉ុន្តែ ការបង្ហាញឆន្ទៈអំពីការលុបចោលចាំបាច់ត្រូវឲ្យបានទៅដល់ភាគីម្ខាងទៀត (ទៅដល់)។ ※មិនតម្រូវឲ្យមានការយល់ព្រមពីភាគីម្ខាងទៀតទេ។

# អានុភាពនៃការលុបចោល(CC358)

(1) សកម្មភាពដែលអាចលុបចោលបាន មានសុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោល សកម្មភាពនោះ។

(2) ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោល សកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។

(3) ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានផ្ដល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះ ត្រូវមានសុពលភាពជាស្ថាពរ។

# សច្ចានុមតិ(CC358)

មានករណីខ្លះមិនចាំបាច់លុបចោលកិច្ចសន្យានោះទេ ដោយសារខ្លឹមសារនៃកិច្ចសន្យាមិនធ្វើឲ្យបាត់បង់ផលប្រយោជន៍ដល់អ្នកមានសិទ្ធិលុបចោល។ ចំពោះករណីបែបនេះ អ្នកមានសិទ្ធិលុបចោលអាចផ្ដល់សច្ចានុមតិបាន។

ក្នុងករណីអ្នកមានសិទ្ធិលុបចោលផ្ដល់សច្ចានុមតិដល់សកម្មភាពដែលអាចលុបចោលបាន (កថាខណ្ឌទី៣)

→សកម្មភាពនោះត្រូវមានសុពលភាពជាស្ថាពរ

# អ្នកមានសិទ្ធិផ្តល់សច្ចានុមតិ·លក្ខខណ្ឌនៃការផ្តល់សច្ចានុមតិ(CC361(1))

អ្នកមានសិទ្ធិលុបចោល អាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន។ ប៉ុន្តែក្នុងករណីដែលលុបចោលសកម្មភាព ដោយយកការបង្ហាញឆន្ទៈដោយមានវិការៈជាមូលហេតុ អ្នកមានសិទ្ធិលុបចោលអាចផ្តល់សច្ចានុមតិបាន...ចាប់តាំងពីពេលបានដឹងអំពីមូលហេតុនៃការលុបចោល។

# សច្ចានុមតិដែលច្បាប់បានកំណត់(CC362)

នៅក្រោយពេលដែលអាចផ្តល់សច្ចានុមតិតាមបញ្ញត្តិនៃមាត្រា ៣៦១ សកម្មភាពដែលអាចលុបចោលបាន ត្រូវចាត់ទុកថា បានផ្តល់សច្ចានុមតិរួចហើយ ក្នុងករណីមានហេតុដូចខាងក្រោមនេះ ៖

ក. ការអនុវត្តកាតព្វកិច្ចទាំងមូល ឬ មួយផ្នែក ចំពោះកាតព្វកិច្ចដែលកើតឡើងដោយសកម្មភាពដែលអាចលុបចោលបាន ឬ ការដាក់ប្រាតិភោគដើម្បីធានាកាតព្វកិច្ចនោះ។

ខ. ការអនុវត្តសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន ឬ ការទាមទារឲ្យភាគីម្ខាងទៀតអនុវត្ត។

# សច្ចានុមតិដែលច្បាប់បានកំណត់(CC362)

គ. អនុប្បទាន ឬ ការចាត់ចែងផ្សេងទៀតនូវសិទ្ធិទាំងមូល ឬមួយផ្នែកចំពោះសិទ្ធិដែលបានទទួលពីសកម្មភាពដែលអាចលុបចោលបាន។

ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើមានឋបនីយថាខ្លួនមិនបានផ្តល់សច្ចានុមតិ នៅពេលដែលហេតុដែលបានកំណត់នៅក្នុងករណីទាំងបីខាងលើនោះ កើតឡើង។

※ក～គ គឺជាសកម្មភាពដែលមានគោលជំហរថា សកម្មភាពដែលអាចលុបចោលបានមានសុពលភាព ហេតុនេះ គេផ្តល់អានុភាពស្មើគ្នានឹងការផ្តល់សច្ចានុមតិ។

# អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល (CC363)

បើសិនជាអ្នកមានសិទ្ធិលុបចោល 「មិនលុបចោល」 ហើយ 「មិនផ្តល់សច្ចានុមតិ」 នោះភាគីម្ខាងទៀតនឹងមិនមានស្ថេរភាព។ ហេតុនេះច្បាប់បានចែងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោលនេះ។

- មិនអនុវត្តសិទ្ធិក្នុងរយៈពេល ៣ឆ្នាំ ចាប់តាំងពីពេលដែលអាចផ្តល់សច្ចានុមតិ
  →សិទ្ធិលុបចោលត្រូវរលត់
- ហួសអំឡុងពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព
  → សិទ្ធិលុបចោលត្រូវរលត់

# ※ពេលដែលអាចផ្ដល់សច្ចានុមតិបានគឺជាអ្វី?

សច្ចានុមតិគឺជា សកម្មភាពដែលបង្ហាញច្បាស់លាស់ថាមិនអនុវត្តសិទ្ធិលុបចោល ដោយបានដឹងថាសកម្មភាពរបស់ខ្លួនជាសកម្មភាពអាចលុបចោលបាន។

↓

ការទទួលស្គាល់ដោយមិនដឹងអំពីហេតុដែលអាចលុបចោលបាន មិនក្លាយជាការផ្ដល់សច្ចានុមតិទេ

↓

ក្រោយពេលដែលអ្នកមានសិទ្ធិលុបចោលដឹងអំពីហេតុដែលអាចលុបចោល

# ករណីដែលកិច្ចសន្យាក្លាយជាមោឃៈ

ប្រព័ន្ធដែលស្រដៀងគ្នានឹងការលុបចោល គឺមោឃភាព។

① ការបង្ហាញឆន្ទៈមិនពិត (CC353)
② ផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ (CC354(1-ក))
③ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ (CC354(1-ខ))
④ ផ្ទុយនឹងទម្រង់នៃច្បាប់ (CC357)

# ករណីដែលកិច្ចសន្យាក្លាយជាមោឃៈ

① ការបង្ហាញឆន្ទៈមិនពិត(CC353)

② ផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ(CC354(1-ក))

③ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ(CC354(1-ខ))

④ ផ្ទុយនឹងទម្រង់នៃច្បាប់(CC357)

# ករណីសិក្សា1 : តើ Y គួរធ្វើបែបណា?



ដី A



X

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដី A ទៅ Y ក្នុងតម្លៃ ១០០០០$ ហេតុនេះ Y ត្រូវបង់ប្រាក់ថ្លៃដី ១០០០០$។



Y

ខ្ញុំមិនចង់បង់ប្រាក់ថ្លៃដី A ទេ ដោយសារតែ X បានមកពឹងខ្ញុំឱ្យធ្វើជាទិញដីនោះពី X ដើម្បីគេចពីការអនុវត្តដោយបង្ខំពីម្ចាស់បំណុលរបស់ X ។

# មោឃភាពដោយការបង្ហាញឆន្ទៈមិនពិត(CC353)

កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិត ដែលត្រូវបានធ្វើឡើង ដោយមានការឃុបឃិតជាមួយនឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ។

# ករណីសិក្សា2:តើ X គួរធ្វើបែបណា?



# មោឃភាពដោយការបង្ហាញឆន្ទៈមិនពិត (CC353(2))

មោឃភាពនៃកិច្ចសន្យាដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ។

# ករណីដែលកិច្ចសន្យាក្លាយជាមោឃៈ

① ការបង្ហាញឆន្ទៈមិនពិត (CC353)

② ផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ (CC354(1-ក))

③ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ (CC354(1-ខ))

④ ផ្ទុយនឹងទម្រង់នៃច្បាប់ (CC357)

# ករណីសិក្សា3: តើ Y គួរធ្វើបែបណា?



ដី A

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដី A ទៅ Y ក្នុងតម្លៃ ១០០០០$ ហេតុនេះ Y ត្រូវបង់ប្រាក់ថ្លៃដី ១០០០០$។



X



Y

X បានលក់ដីមកឲ្យខ្ញុំ ដែលមានកិច្ចសន្យាឲ្យរក្សាឈ្មោះក្នុងគោលបញ្ជីដីធ្លីដដែល ហើយផ្ទេរកម្មសិទ្ធិលើដីមកឲ្យខ្ញុំ ហេតុនេះ ខ្ញុំមិនចង់បង់ប្រាក់ថ្លៃដីទេ។

លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង(CC135)

ទោះបីមានបញ្ញត្តិនៃមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) និង មាត្រា ១៣៤ (លក្ខខណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) នៃក្រមនេះ ក៏ដោយ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មិនមានអានុភាព បើមិនបានចុះបញ្ជី ដោយយោងតាមបញ្ញត្តិនៃច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត ស្ដីពីការចុះបញ្ជី។

→ កិច្ចសន្យារវាង X និង Y គឺផ្ទុយនឹងមាត្រា135 នៃក្រមរដ្ឋប្បវេណី

# មោឃភាពដោយផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ (CC354(1-ក))

ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈក្នុងករណីខាងក្រោមនេះ ៖

ក. អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ។

ខ. អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។

# ករណីដែលកិច្ចសន្យាក្លាយជាមោឃៈ

① ការបង្ហាញឆន្ទៈមិនពិត (CC353)
② ផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ (CC354(1-ក))
③ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ (CC354(1-ខ))
④ ផ្ទុយនឹងទម្រង់នៃច្បាប់ (CC357)

# ករណីសិក្សា4 : តើ Y គួរធ្វើបែបណា?



# អាសអាភាសដោយផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ(CC354(1-២))

ទោះបីជាភាគីនៃកិច្ចសន្យាបានធ្វើការបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈក្នុងករណីខាងក្រោម ៖

ក. អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ។

ខ. អត្ថន័យនៃកិច្ចសន្យានោះផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ល្អ។

# ករណីដែលកិច្ចសន្យាក្លាយជាមោឃៈ

① ការបង្ហាញឆន្ទៈមិនពិត (CC353)

② ផ្ទុយនឹងបញ្ញត្តិអនុវត្តដោយបង្ខំ (CC354(1-ក))

③ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ (CC354(1-ខ))

④ ផ្ទុយនឹងទម្រង់នៃច្បាប់ (CC357)

# ករណីសិក្សា 5: តើ Y គួរធ្វើបែបណា?



ដី A



X

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ ខ្ញុំបានលក់ដី A ទៅ Y ក្នុងតម្លៃ ១០០០០$ ហេតុនេះ Y ត្រូវបង់ប្រាក់ថ្លៃដី ១០០០០$មក។

ខ្ញុំមិនចង់បង់ប្រាក់ថ្លៃដីទេ ដោយសារតែកិច្ចសន្យានោះមានខ្លឹមសារដែលតម្រូវឲ្យផ្ទេរកម្មសិទ្ធិលើដី A មកឲ្យខ្ញុំដោយមិនធ្វើលិខិតយថាភូត។



Y

# មោឃភាពដោយផ្ទុយនឹងទម្រង់ច្បាប់
(CC357)

ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈ ដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឲ្យមាន ដោយក្រមនេះ ឬ ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។

# ភាពខុសគ្នានៃការលុបចោល និង មោឃភាព

ប្រសិនបើប្រៀបធៀបប្រព័ន្ធទាំង ២ នេះ មោឃភាពគឺមានកម្រិតនៃវិការៈធ្ងន់ធ្ងរជាង ហេតុនេះ វាមានភាពខុសគ្នាដូចខាងក្រោម ៖

| | | **លុបចោល** | **មោឃភាព** |
|---|---|---|---|
| ជនដែលអាចអះអាងបាន | | អ្នកដែលបានបង្ហាញឆន្ទៈមានវិការៈ | មិនកម្រិត |
| វិធីអះអាង | បង្ហាញឆន្ទៈ | ត្រូវការ | មិនត្រូវការ |
| | សាលក្រម/សាលដីកា | មិនត្រូវការ | មិនត្រូវការ |
| សច្ចានុមតិ | | អាច | មិនអាច |
| អាជ្ញាយុកាលរំលត់ | | មាន | មិនមាន |